ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថាស្វាគមន៍
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីជប់លៀងអាហារពេលល្ងាចរបស់
# ការិយាល័យតំណាង Bank of Tokyo-Mitsubishi UFJ
# រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២

**សូមគោរព ៖**

- **លោក Tatsuya Machida ទីប្រឹក្សា ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា**
- **លោក Takashi Morimura អគ្គនាយករង និងតំណាងនាយកនៃអង្គភាពអាជីវកម្មសកលរបស់ Bank of Tokyo-Mitsubishi UFJ**
- **លោក Takashi Morisaki នាយកប្រតិបត្តិរបស់ Bank of Tokyo-Mitsubishi UFJ ប្រចាំនៅកម្ពុជា**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី**

ថ្ងៃនេះ ខ្ញុំមានកិត្តិយសប្រកបដោយក្តីសោមនស្សរីករាយជាទីបំផុត ដោយបានការអញ្ជើញចូលរួមក្នុងពិធីជប់លៀងអាហារពេលល្ងាចរបស់ការិយាល័យតំណាង Bank of Tokyo-Mitsubishi UFJ នាពេលនេះ ។

តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំសូមស្វាគមន៍ និងអបអរសាទរចំពោះគណៈគ្រប់គ្រង Bank of Tokyo-Mitsubishi UFJ ដែលមានការិយាល័យតំណាងរបស់ខ្លួននៅរាជធានីភ្នំពេញ ។ ជាមួយគ្នានេះដែរ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះថ្នាក់ដឹកនាំ និងវិនិយោគិននៃព្រះរាជាណាចក្រជប៉ុន ដែលបានគាំទ្រចំពោះគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងបានជំរុញឲ្យមានការវិនិយោគកាន់តែច្រើនឡើងនៅកម្ពុជា ជាពិសេសវិស័យធនាគារនិងហិរញ្ញវត្ថុដែលមានសន្ទុះគួរឲ្យកត់សំគាល់ក្នុងពេលថ្មីៗនេះ ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការបើកការិយាល័យតំណាង Bank of Tokyo-Mitsubishi UFJ នៅកម្ពុជាបានឆ្លុះបញ្ចាំងឲ្យឃើញពីជំនឿទុកចិត្តរបស់វិនិយោគិនជប៉ុន មកលើសភាពការណ៍ទូទៅនៅកម្ពុជាក៏ដូចជាស្ថេរភាពនយោបាយ ការរីកចំរើនខាងសេដ្ឋកិច្ច ជាពិសេសវឌ្ឍនៈភាពនៃវិស័យធនាគារនៅកម្ពុជា និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ប្រជាជន និងរាជរដ្ឋាភិបាលជប៉ុន ដែលបានបន្តផ្តល់នូវជំនួយឧបត្ថម្ភទាំងផ្នែកមនុស្សធម៌ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលជាការចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងប្រទេសកម្ពុជា ។

## ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី

ក្នុងខែមេសា ឆ្នាំ២០១២ ព្រះរាជាណាចក្រកម្ពុជាបានទទួលកិត្តិយសយ៉ាងធំធេងក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី២០ ដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។ ស្របពេលដែលសេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនជាលំដាប់នាពេលបច្ចុប្បន្ននេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាប្រព័ន្ធធនាគារកម្ពុជាទាំងមូលមានស្ថានភាពល្អប្រសើរគួរឲ្យកត់សំគាល់ ។ គិតមកដល់បច្ចុប្បន្ននេះ ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជចំនួន ៣២ ធនាគារឯកទេសចំនួន ៧ ការិយាល័យតំណាងធនាគារបរទេសចំនួន ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣២ ក្នុងនោះគ្រឹះស្ថានចំនួន ៧ អាចប្រមូលប្រាក់បញ្ញើពីសាធារណៈជន និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុចុះបញ្ជីចំនួន ២៨ ។ ការអភិវឌ្ឍវិស័យធនាគារបានឆ្លុះបញ្ចាំងពីទំនុកចិត្តកាន់តែច្រើនជាងមុនពីសាធារណៈជនទាំងក្នុង និងក្រៅប្រទេស ដែលធ្វើឲ្យទំហំនៃប្រតិបត្តិករ និងចំនួនអតិថិជនរបស់គ្រឹះស្ថានធនាគារមានការកើនឡើងគួរឲ្យកត់សំគាល់ ។ គិតត្រឹមដំណាច់ឆ្នាំ២០១១ នៅក្នុងប្រព័ន្ធធនាគារ កំណើនប្រាក់បញ្ញើនិងឥណទានបានកើនឡើង ២០,៤១% និង ៣៣,៤៩% រៀងគ្នា ប្រៀបធៀបទៅនឹងឆ្នាំ ២០១០ ។ ឆ្លើយតបទៅនឹងកំណើនអតិថិជននិងទំហំប្រតិបត្តិការ គ្រឹះស្ថានធនាគារនិមួយៗបានពង្រីកបណ្តាញសាខារបស់ខ្លួនតាមបណ្តាខេត្តក្រុងពេញផ្ទៃប្រទេស ដែលគិតមកត្រឹមដំណាច់ឆ្នាំ២០១១ បណ្តាញសាខារបស់គ្រឹះស្ថានធនាគារមានចំនួន ៤២១ កន្លែង ។

## ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី

ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងវប្បធម៌ប្រកួតប្រជែងដោយស្មើភាពរវាងធនាគារ និងធនាគារ និងសហការឲ្យកាន់តែប្រសើរឡើងជាមួយអាជ្ញាធរត្រួតពិនិត្យវិស័យហិរញ្ញវត្ថុដទៃទៀត ដើម្បីបង្កើនតម្លាភាព ប្រសិទ្ធភាព ព្រមទាំងជំនឿទុកចិត្តរបស់សាធារណៈជនមកលើប្រព័ន្ធធនាគារ ដែលជាបច្ច័យដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាឲ្យមានការរីកចំរើនជាលំដាប់ ។

ខ្ញុំមានជំនឿថា ការិយាល័យតំណាង Bank of Tokyo-Mitsubishi UFJ នឹងក្លាយខ្លួនជាធនាគារពាណិជ្ជក្នុងពេលឆាប់ៗនៅកម្ពុជា ហើយនឹងក្លាយជាដៃគូរអភិវឌ្ឍដ៏ល្អមួយជាមួយរាជរដ្ឋាភិបាលកម្ពុជា និងជាប្រតិបត្តិករល្អជាមួយធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តបទប្បញ្ញត្តិយ៉ាងខ្ជាប់ខ្ជួន និងជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុល្អជាមួយអតិថិជនទូទៅក្នុងការពង្រីកប្រតិបត្តិការរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីមេត្រី**

ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងស្វាគមន៍ចំពោះថ្នាក់ដឹកនាំរបស់ការិយាល័យតំណាង Bank of Tokyo-Mitsubishi UFJ ហើយខ្ញុំសង្ឃឹមថា ការិយាល័យតំណាងនេះនឹងមានដំណើរការល្អ ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនទាំងនៅពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត ។ ខ្ញុំសូមជូនពរឲ្យការិយាល័យតំណាងទទួលបានការគាំទ្រ និងជំនឿទុកចិត្តបន្ថែមទៀតពីសាធារណជនជាតិ និងអន្តរជាតិ ។

ជាទីបញ្ចប់ ឆ្លៀតក្នុងឱកាសដ៏ឱឡារិកនេះ ខ្ញុំសូមគោរពជូនពរឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ជាភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ សូមមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច និងសូមជូនពរថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកទាំងអស់របស់ការិយាល័យតំណាង Bank of Tokyo-Mitsubishi UFJ សូមមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងប្រតិបត្តិការរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពជារៀងរហូត ។

**សូមអរគុណ**!